# របាយការណ៍ស្តីអំពីកាប្រឈមមួយចំនួន ដែលបានជួបប្រទះនៅក្នុងវគ្គបណ្តុះបណ្តាល គ្រូបង្គោលថ្នាក់ជាតិ

## ២៩ មិថុនា-៧ កក្កដា ២០០៩

## បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំការប្រជុំបូកសរុបមួយ ដែលមានការចូលរួមពីបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកជំនាញអន្តរជាតិ និងអ្នកសម្របសម្រួលទាំងអស់ ។ សេចក្តីសង្ខេបអំពីការប្រឈម ដែលបានជួបប្រទះនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិមានដូចខាងក្រោម ៖

១. លោកគ្រូអ្នកគ្រូចង់ឲ្យមានការបង្រៀនគំរូនៅក្នុងក្រុមធំ ដើម្បីឲ្យមានភាពស្របគ្នានិងច្បាស់លាស់នៅក្នុងការបង្រៀនមេរៀននីមួយៗ ។

២. ជ្រើសរើសមេរៀនមួយចេញពីជំពូកនីមួយៗនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ដើម្បីធ្វើជាមេរៀនគំរូ ហើយសិក្ខាកាមទាំងអស់ត្រូវចូលរួមធ្វើមេរៀនគំរូនេះ ដើម្បីជៀសវាងការដាក់ឲ្យអនុវត្តនូវវិធីសាស្ត្រណាមួយ ដោយនរណាម្នាក់ ។

៣. អ្នកសម្របសម្រួលគួរជួបប្រជុំគ្នាមួយថ្ងៃមុន ដើម្បីសម្រេចថាតើត្រូវជ្រើសរើសមេរៀនណាមួយធ្វើជាមេរៀនគំរូ និងថាតើវិធីសាស្ត្របង្រៀនណាមួយដែលគួរប្រើប្រាស់ ។ ជាទូទៅក្រុមតូចៗមានប្រសិទ្ធិភាពជាង ក្នុងការធ្វើឲ្យថ្នាក់រៀនមានដំណើរការ និងការពិភាក្សា ។

៤. វគ្គបណ្តុះបណ្តាលគួរបូរួមបញ្ចូលវិធី៥ជំហាន និងកំរិតនៃការគិតទាំង៦ Taxonomy នៅក្នុងការធ្វើមេរៀនគំរូ ។

៥. សិក្ខាកាមទាំងអស់មិនទាន់យល់ច្បាស់ ពីគោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ ព្រោះកម្មវត្ថុមិនត្រូវបានបង្ហាញឲ្យបានច្បាស់លាស់ មុនពេលនិងក្នុងកំឡុងពេលនៃការបង្រៀន ។

៦. មានការពិភាក្សាច្រើនលើសលុបទៅលើផ្នែកប្រវត្តិសាស្ត្រ ។ អ្នកសម្របសម្រួលត្រូវគ្រប់គ្រងស្ថានការណ៍នេះ និងត្រូវដឹកនាំការពិភាក្សាទៅមុខទៀត ។ ប្រសិនបើសិក្ខាកាមសួរសំណួរចាក



DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia

Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ប្រធានបទច្រើនពេក សិក្ខាកាមទាំងអស់អាចលើកសំណួរនេះទៅសួរអ្នកជំនាញនាពេលសម្រាក ឬពេលពិសារអាហារថ្ងៃត្រង់ ។

៧. កាលវិភាគនៃវគ្គបណ្តុះបណ្តាល គួរតែត្រូវបានកំណត់ជាមុននិងឲ្យបានច្បាស់លាស់ សម្រាប់សិក្ខាកាមនិងអ្នកជំនាញអន្តរជាតិទាំងអស់ ។

៨. ត្រូវផ្តល់ការរំពឹងទុកច្បាស់លាស់ដល់អ្នកចូលរួមទាំងអស់ ជាពិសេសសិក្ខាកាម ។ ក្រសួងអប់រំបានបញ្ជាក់ច្បាស់លាស់ចំពោះចំណុចនេះ ដែលថាសិក្ខាកាមទាំងអស់ត្រូវចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៃគម្រោងនេះ ហើយក្លាយទៅជាគ្រូបង្គោលថ្នាក់ជាតិ ដែលមានសមត្ថភាពក្នុងការបណ្តុះបណ្តាលបន្តទៅកាន់គ្រូបង្គោលថ្នាក់ខេត្ត និងលោកគ្រូអ្នកគ្រូប្រមាណ៣ពាន់នាក់នៅទូទាំងប្រទេស ។

៩. មិនមានការបញ្ជាក់ឲ្យបានច្បាស់លាស់ថា គ្រូបង្គោលថ្នាក់ជាតិមិនតម្រូវឲ្យសរសេរសៀវភៅណែនាំគ្រូថ្មីមួយទៀត បែកចេញពីសៀវភៅណែនាំសម្រាប់គ្រូបង្រៀនដែលមានស្រាប់នោះទេ ។

១០. អត្ថបទរបស់វាគ្មិនគួរតែត្រូវបានសម្រួលឃ្លា និងសង្ខេបឲ្យនៅត្រឹម២ឬ៣ទំព័រ ដើម្បីធានាឲ្យបានថា សិក្ខាកាមមានលទ្ធភាពក្នុងការចាប់យកចំណុចសំខាន់ៗនៅក្នុងអត្ថបទទាំងនោះ បន្ទាប់ពីអានរួច ។

១១. សិក្ខាកាមទាំងអស់ត្រូវការពេលវេលាបន្ថែម ដើម្បីអានអត្ថបទទាំងនោះមុនម៉ោងសិក្សា ។

១២. យើងអាចឲ្យសិក្ខាកាមម្នាក់ៗផ្លាស់ប្តូរគ្នាអានអត្ថបទឲ្យឮៗនៅក្នុងថ្នាក់ ដើម្បីធានាឲ្យបានថាអ្នកទាំងអស់គ្នាបានអានអត្ថបទ ហើយមានគំនិតក្នុងការពិភាក្សា ។

១៣. អ្នកសម្របសម្រួលត្រូវផ្តល់សំណួរមួយចំនួន ដើម្បីពិភាក្សាអំពីអត្ថបទដែលបានអាន ។

១៤. រូបថតដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ត្រូវដាក់ចំណងជើងឲ្យបានច្បាស់លាស់ ។ សិស្សអាចសួរសំណួរជាច្រើនទាក់ទងនឹងរូបថត ។ ប្រសិនបើគ្រូត្រូវការព័ត៌មានបន្ថែម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់ជូន ។

១៥. យើងគួរចំណាយពេលវេលាបន្ថែមដល់សិក្ខាកាមក្នុងការសួរសំណួរ ដើម្បីស្វែងយល់ពីប្រវត្តិសាស្ត្រ និងវិធីសាស្ត្របង្រៀន ។

១៦. ឧបសគ្គចម្បងមួយ គឺសមភាពរវាងប្រវត្តិសាស្ត្រនិងវិធីសាស្ត្របង្រៀន ។ សិក្ខាកាមបន្តសួរសំណួរច្រើន តែទៅលើប្រវត្តិសាស្ត្រ ។

១៧. យើងត្រូវបញ្ជាក់ឲ្យបានច្បាស់ថា គ្រូបង្គោលថ្នាក់ជាតិនឹងមិនសិក្សាស៊ីជម្រៅទៅលើប្រវត្តិសាស្ត្រនោះទេ។ យើងមិនមែនរៀនដើម្បីក្លាយទៅជាអ្នកប្រវត្តិសាស្ត្រទេ ដូច្នេះយើងនឹងមិនពិភាក្សាស៊ីជម្រៅទៅលើប្រវត្តិសាស្ត្រនោះទេ។

១៨. អ្នកសម្របសម្រួលត្រូវធ្វើយ៉ាងណាឲ្យសិក្ខាកាមទាំងអស់ ផ្តោតការយកចិត្តទុកដាក់ទៅលើវិធីសាស្ត្រនៃការបង្រៀនប្រវត្តិសាស្ត្រនៅក្នុងថ្នាក់រៀន ឲ្យបានច្រើនជាងការផ្តោតការយកចិត្តទុកដាក់ទៅលើប្រវត្តិសាស្ត្រ។

១៩. ចាំបាច់ត្រូវកំណត់អំពីទំហំនៃការពិភាក្សាទៅលើប្រវត្តិសាស្ត្រឲ្យបានច្បាស់លាស់។ ការពិភាក្សាទៅលើប្រវត្តិសាស្ត្រ ត្រូវតែស្ថិតនៅក្នុងវង្វង់នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

២០. យើងត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើសៀវភៅណែនាំសម្រាប់គ្រូបង្រៀន។ និយាយម្យ៉ាងទៀត យើងត្រូវផ្តោតជាសំខាន់ទៅលើគរុកោសល្យនៃការបង្រៀន។

២១. អ្នកសម្របសម្រួលត្រូវគ្រប់គ្រងការរំពឹងទុករបស់សិក្ខាកាម។

២២. យើងគួរតែបញ្ជាក់ឡើងវិញថា សៀវភៅនេះមានចំណងជើងថា"ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ដែលមានការបកស្រាយខុសៗគ្នាច្រើន។

២៣. អ្នកសម្របសម្រួលត្រូវតែធ្វើទៅតាមកាលវិភាគដែលបានកំណត់ទុក។ ទោះជាយ៉ាងនេះក្តី វាប្រាកដជាមានការប្រែប្រួលមួយចំនួន។

២៤. នៅគ្រប់ក្រុមទាំងអស់ មានអ្នកនិយាយច្រើនតែឯង និងអ្នកមិននិយាយស្ទើរសោះ ទោះជាយ៉ាងនេះក្តី លោកគ្រូអ្នកគ្រូទាំងអស់មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការពិភាក្សា។

២៥. ក្រុមតូចៗមានការបើកទូលាយជាង ដែលការបើកទូលាយបែបនេះមិនសូវមាននៅក្នុងក្រុមធំទេ។

២៦. វគ្គបណ្តុះបណ្តាលមិនបានរួមបញ្ចូលទស្សនសង្គមនៃអំពើប្រល័យពូជសាសន៍។ យើងគួរបញ្ចូលការពិភាក្សាទៅលើការប្រើប្រាស់អំណាច ការបញ្ចូលមនោគមវិជ្ជាទៅលើកូនក្មេង ហេតុអ្វីបានជាយើងជ្រើសរើសកូនក្មេងឲ្យទៅធ្វើការមិនសមរម្យ។ យើងត្រូវបញ្ជាក់ថា បញ្ហាទាំងអស់នេះ មិនមែនកើតមានឡើងតែនៅកម្ពុជានោះទេ វាកំពុងតែកើតឡើងនាពេលបច្ចុប្បន្ន តើយើងត្រូវនិយាយទៅកាន់កូនក្មេងទាំងអស់នោះដោយរបៀបណា?

២៧. យើងគួរធ្វើការជ្រើសរើសគ្រូបង្រៀនដែលមានបទពិសោធន៍ច្រើន។

២៨. ឌី ខាំបូលី បានធ្វើកិច្ចការយ៉ាងល្អនៅក្នុងការធ្វើការងារ និងការនិយាយស្តីជាមួយលោកគ្រូអ្នកគ្រូ ប្រកបដោយការទូតនិងការគោរព ហើយយើងត្រូវតែបន្តអនុវត្តឥរិយាបថបែបនេះតទៅទៀត ។

២៩. ឌី ខាំបូលី មិនទាន់មានភាពចាស់ទុំគ្រប់គ្រាន់ក្នុងការបញ្ឈប់ការពិភាក្សាទាំងឡាយណា ដែលមិនស្ថិតនៅក្នុងរបៀបវារៈនៃការពិភាក្សាឡើយ ។

៣០. តើអ្វីខ្លះជាសារៈសំខាន់ និងឧបសគ្គនៃការប្រើប្រាស់វិធីសាស្ត្រ «សិស្សមជ្ឈមណ្ឌល»?

៣១. សិក្ខាកាមមួយចំនួនបានបង្ហាញការខ្វល់ខ្វាយចំពោះវិធីសាស្ត្រ «សិស្សមជ្ឈមណ្ឌល» ថា មិនអាចអនុវត្តទៅបាននៅក្នុងថ្នាក់ធំ ដែលមានសិស្សច្រើននោះទេ ។

៣២. យើងគួរតែឃ្លាតចេញឆ្ងាយពីទ្រឹស្តី ហើយផ្តោតទៅលើការអនុវត្ត ។

៣៣. សិក្ខាកាមទាំងអស់ត្រូវមានចិត្តបើកទូលាយ ទៅលើវិធីសាស្ត្ររបស់ខ្លួន ។

៣៤. សៀវភៅណែនាំសម្រាប់គ្រូបង្រៀន ត្រូវតែបង្រួមនិងធ្វើឲ្យសាមញ្ញបំផុត ។

៣៥. សិក្ខាកាមបង្ហាញពី ភាពខ្វល់ខ្វាយចំពោះបញ្ហាសម្ភារៈឧបទេសក្នុងការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ។ យើងគួរតែមានឧបករណ៍បញ្ចាំងខ្សែភាពយន្ត ខ្មៅដៃ ផែនទីកម្ពុជាប្រជាធិបតេយ្យ និងកាតពណ៌ សម្រាប់ពាក់ ។

៣៦. យើងត្រូវសុំឲ្យសិក្ខាកាមទាំងអស់ បំពេញទម្រង់វាយតម្លៃនៃវគ្គបណ្តុះបណ្តាលពេលបញ្ចប់វគ្គ ។

៣៧. យើងត្រូវភ្ជាប់ប្រព័ន្ធអ៊ីនធឺណែតនៅក្នុងសាលសិក្ខាសាលា ។

៣៨. សិក្ខាកាមបានស្នើសុំសៀវភៅសន្ទានុក្រម សម្រាប់មើលពាក្យបច្ចេកទេសពិបាកៗ ។

៣៩. យើងត្រូវមានការប្រុងប្រយ័ត្នចំពោះការសន្យាផ្សេងៗ ។ ឌី ខាំបូលី បានសន្យាថានឹងរៀបចំសៀវភៅសន្ទានុក្រម ហើយប្រហែលជានឹងអាចផ្តល់ជូនសៀវភៅរូបភាពមួយទៀត ។ សិក្ខាកាមបានប្រកាន់ខ្ជាប់ខ្ជួនចំពោះពាក្យសន្យាទាំងនេះ ។

៤០. បន្ទាប់ពីវគ្គបណ្តុះបណ្តាល សិក្ខាកាមហាក់ដូចជាមិនមានភាពប្រាកដប្រជាថា តើខ្លួនទទួលបានអ្វីខ្លះពីវគ្គបណ្តុះបណ្តាលនេះ? មានការយល់មិនស្របគ្នាចំពោះគោលដៅនៃវគ្គបណ្តុះបណ្តាល ហើយសិក្ខាកាមហាក់ដូចជាដឹងនូវការរំពឹងទុកនៅថ្ងៃចុងក្រោយ ។ សិក្ខាកាមមួយចំនួនបានចោទជាសំណួរថា «តើយើងត្រូវបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដោយរបៀបណា? តើយើងត្រូវធ្វើ Power Point ដូចដែល ឌី ខាំបូលី បានធ្វើក្នុងពេលធ្វើបទបង្ហាញ ដែរឬយ៉ាងណា?» ។

៤១. គ្រូបង្គោលថ្នាក់ជាតិ ព្រួយបារម្ភណ៍ចំពោះការចុះទៅបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ។

៤២. គួសបញ្ជាក់អំពីគោលបំណងធំនៃការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

៤៣. សិក្ខាកាមចង់បានរូបភាពបន្ថែមទៀត ដូចជារូបភាពនៅថ្ងៃជម្លៀស និងផែនទីរបស់កម្ពុជាប្រជាធិបតេយ្យ ។ យើងគួរតែផ្តល់ជូនសិក្ខាកាមនូវកញ្ចប់មួយ ដែលរួមមានរូបភាពនៅថ្ងៃជម្លៀស រូបភាពនៅថ្ងៃរំលំត្រឡប់ និងផែនទីកម្ពុជាប្រជាធិបតេយ្យ ។

៤៤. ជំពូកទាំងឡាយនៅក្នុងសៀវភៅណែនាំគ្រូ គួរតែត្រូវបែងចែកទៅតាមម៉ោងព្រឹកនិងរសៀល ដើម្បីឲ្យមានការតភ្ជាប់ពីជំពូកមួយទៅជំពូកមួយទៀត ។

៤៥. មិនមានការតភ្ជាប់គ្នាពីមេរៀនមួយទៅមេរៀនមួយទៀត នៅក្នុងការឡើងធ្វើមេរៀនគំរូ ។